*[សូមផ្ទៀងផ្ទាត់ តាមការអាន]*

# សុន្ទរកថា
# អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី, រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ជាប្រធានកិត្តិយស សមាគមសង្គហៈមិត្ត បុគ្គលិក មន្ត្រីរាជការ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
# ថ្លែងក្នុង
# ពិធីសំណេះសំណាលជាមួយនិវត្តជន នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

រាជធានីភ្នំពេញ, ថ្ងៃអង្គារ ១ កើត ខែចេត្រ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧
ត្រូវនឹងថ្ងៃទី ៩ ខែ មេសា គ.ស. ២០២៤

- ឯកឧត្តម, លោកជំទាវ, ថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ;
- ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី, ប្រធាន, អនុប្រធាន, សមាជិក-សមាជិកា នៃក្រុមប្រឹក្សាភិបាលសមាគមសង្គហៈមិត្ត បុគ្គលិក មន្ត្រីរាជការ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ;
- ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី, មន្ត្រីរាជការ និង និវត្តជន នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ, ជាទីមេត្រី និង ជាទីនឹករលឹក!

ថ្ងៃនេះ, ខ្ញុំពិតជាមានសេចក្តីរីករាយយ៉ាងក្រៃលែង ដោយបានមកចូលរួមជាអធិបតី ក្នុង **ពិធីសំណេះសំណាលជាមួយនិវត្តជន នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ** ដែលត្រូវបានរៀបចំឡើង ក្រោមការសម្របសម្រួលរបស់សមាគមសង្គហៈមិត្ត បុគ្គលិក មន្ត្រីរាជការ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ, ដោយមានការចូលរួមពីថ្នាក់ដឹកនាំ និង មន្ត្រីរាជការ, ជាពិសេស

វត្តមានរបស់លោកអ៊ំ, លោកពូ, អ្នកមីង និង បងៗ ដែលជាអតីតមន្ត្រីរាជការ ធ្លាប់បម្រើការងារក្រោមឱវាទក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សរុបប្រមាណ ៥០០ រូប ។ ខ្ញុំសូមស្វាគមន៍យ៉ាងកក់ក្តៅ ចំពោះឯកឧត្តម, លោកជំទាវ, លោក, លោកស្រី, ជាពិសេស លោកអ៊ំ, លោកពូ, អ្នកមីង និង បងៗ ជានិវត្តជនទាំងអស់ ដែលបានឆ្លៀតពេលដ៏មានតម្លៃ អញ្ជើញចូលរួមក្នុងពិធីជួបជុំរបស់យើង នាថ្ងៃនេះ ។

ពិធីសំណេះសំណាលដ៏មានអត្ថន័យ ដែលកំពុងប្រព្រឹត្តទៅ នាពេលនេះ ត្រូវបានរៀបចំឡើង ក្នុងគោលបំណងចម្បង ចំនួន ២ គឺ៖ **ទី១.** ដើម្បីរំលែកចំណង «**មិត្តភាព, សាមគ្គីភាព និង សង្គហៈធម៌**» រវាងមន្ត្រីរាជការជំនាន់មុន និង មន្ត្រីរាជការបច្ចុប្បន្ន ប្រកបដោយសេចក្តីនឹករលឹក, ភាពកក់ក្តៅ និង ភាពស្និទ្ធស្នាល, និង ដើម្បីបង្ហាញអំពីការគិតគូរដល់អតីតមន្ត្រីរាជការ ដែលធ្លាប់មានគុណបំណាច់ជាច្រើនឥតគណនា ក្នុងការបម្រើការងារជូនក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ក៏ដូចជា ជូនរាជរដ្ឋាភិបាល នាពេលកន្លងទៅ ។ បន្ថែមលើនេះ, កម្មវិធីនាពេលនេះ ក៏ជាឱកាសដ៏កម្រមួយ ដែលលោកអ៊ំ, លោកពូ, អ្នកមីង និង បងៗ ជានិវត្តជនទាំងអស់ បានជួបប្រាស្រ័យទាក់ទងគ្នាដោយផ្ទាល់, បានសួរសុខទុក្ខគ្នាទៅវិញទៅមក និង បានរំលឹកអំពីអនុស្សាវរីយ៍ល្អៗ ក្នុងការបំពេញបេសកកម្មបម្រើជាតិជាមួយគ្នា នាពេលកន្លងទៅ; និង **ទី២.** ដើម្បីអបអរសាទរពិធីបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិខ្មែរ, ឆ្នាំរោង ឆស័ក ពុទ្ធសករាជ ២៥៦៨, ដែលនឹងចូលមកដល់ក្នុងពេលដ៏ខ្លីខាងមុខ ។ នេះ គឺជាការជួបជុំលើកទី ២ បន្ទាប់ពីការជួបជុំលើកទី ១ កាលពីថ្ងៃទី ៤ ខែ មេសា ឆ្នាំ ២០២៣ កន្លងទៅ ក្រោយពីខកខានអស់មួយរយៈ ដោយសារការរីករាលដាលនៃជំងឺកូវីដ-១៩ ។

## ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី!

ខ្ញុំសូមយកឱកាសដ៏ថ្លៃថ្លានេះ រំលឹកជូនសមាជិក-សមាជិកានៃអង្គពិធី ជ្រាបថា ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ចាត់ទុកសមាគមសង្គហៈមិត្ត ជាស្ពានសម្រាប់ផ្សារភ្ជាប់ទំនាក់ទំនងដ៏សំខាន់ រវាងអតីតមន្ត្រីរាជការ និង មន្ត្រីរាជការបច្ចុប្បន្ន ។ យន្តការទំនាក់ទំនងនេះ ត្រូវបានបង្កើតឡើង កាលពីឆ្នាំ ២០១១ ក្រោមគំនិតផ្តួចផ្តើមដ៏ពិសិដ្ឋ របស់ **ឯកឧត្តម កិត្តិបវរិក្សបណ្ឌិត គាត ឈន់** អតីតឧបនាយករដ្ឋមន្ត្រី, រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ, បច្ចុប្បន្នជាប្រធានកិត្តិយស ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ។ **ឯកឧត្តមកិត្តិបវិរក្សបណ្ឌិត** គឺជាស្ថាបនិកកិត្តិយស ដ៏មានគុណូបការៈក្រៃលែង របស់សមាគម

សង្គហៈមិត្ត បុគ្គលិក មន្ត្រីរាជការ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។ ដោយឡែក, រូបខ្ញុំ, ក្នុងនាមជាស្ថាបនិកកិត្តិយសមួយរូបផងដែរ, ក៏នៅតែប្តេជ្ញាចិត្តខ្ពស់ ក្នុងការបន្តខិតខំថែរក្សាកេរដំណែលដ៏ផូរផង់នេះ តរៀងទៅ ក្នុងគោលបំណងផ្តល់ការឧបត្ថម្ភគ្នាទៅវិញទៅមក, ពង្រឹងចំណងមិត្តភាព-សាមគ្គីភាព ឱ្យកាន់តែរឹងមាំ, ព្រមទាំងជួយឧបត្ថម្ភគាំទ្រ, ទាំងហិរញ្ញ-វត្ថុ, សម្ភារៈ និង ស្មារតី, រវាងសមាជិក-សមាជិកាទាំងអស់របស់សមាគម ដែលជាបុគ្គលិក មន្ត្រីរាជការ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ក្រោមបាវចនា **ចំនួន ៣** គឺ ៖ **«មិត្តភាព, សាមគ្គីភាព និង សង្គហៈធម៌»** ។

## ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី!

រាជរដ្ឋាភិបាលកម្ពុជា, ក្នុងនីតិកាលកន្លងទៅ, ក្រោមការដឹកនាំដ៏ឈ្លាសវៃ ប្រកបដោយគតិបណ្ឌិត និង ចក្ខុវិស័យវែងឆ្ងាយ របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**, **អតីតនាយករដ្ឋមន្ត្រី និង បច្ចុប្បន្ន ជាប្រធានព្រឹទ្ធសភា**, ក៏ដូចជា ក្នុងនីតិកាលទី ៧, ក្រោមការដឹកនាំដ៏ស្វាហាប់ និង ឈ្លាសវៃ របស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**, **នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**, ដែលជាអគ្គមគ្គុទ្ទេសក៍វ័យក្មេងដ៏ឆ្នើម និង ពោរពេញដោយសមត្ថភាព, ចំណេះដឹង និង ថាមពល, មិនត្រឹមតែមិនបានមើលរំលងគុណបំណាច់របស់និវត្តជនប៉ុណ្ណោះទេ, ប៉ុន្តែ ថែមទាំងបានបង្កើនការយកចិត្តទុកដាក់ចំពោះនិវត្តជន ជាបន្តបន្ទាប់ទៀតផង ។ ក្នុងន័យនេះ, រាជរដ្ឋាភិបាល បានខិតខំដំឡើងប្រាក់បៀវត្ស, ប្រាក់បំណាច់មុខងារ និង របបសន្តិសុខសង្គម ជូនមន្ត្រីរាជការស៊ីវិល, កង-កម្លាំងប្រដាប់អាវុធ, និវត្តជន និង មន្ត្រី-បុគ្គលិកគ្រប់ប្រភេទ ព្រមទាំងបានបង្កើនប្រាក់-សោធនប្រចាំខែ សម្រាប់អតីតមន្ត្រីរាជការស៊ីវិល និង អតីតយុទ្ធជន ទៅតាមលទ្ធភាពនៃថវិកាជាតិ ។ ជាក់ស្តែង, នៅឆ្នាំ ២០២៣, បៀវត្សអប្បបរមា សម្រាប់មន្ត្រីរាជការទូទៅត្រូវបានដំឡើងដល់ ១ លាន ៣ សែនរៀល និង សម្រាប់គ្រូបង្រៀន និង គ្រូពេទ្យ ត្រូវបានដំឡើងដល់ ១ លាន ៤ សែនរៀល ខណៈដែលបៀវត្សអប្បបរមា ក្នុងឆ្នាំ ២០១៥ មានចំនួនប្រមាណជាង ៣០ ម៉ឺនរៀលតែប៉ុណ្ណោះ, នេះម្យ៉ាង; ម្យ៉ាងទៀត, ទោះបីជាត្រូវបន្តប្រឈមនឹងស្លាកស្នាមនៃវិបត្តិជំងឺកូវីដ-១៩ និង ភាពថមថយនៃកំណើនសេដ្ឋកិច្ច ក្តី, ក៏

រាជរដ្ឋាភិបាល នីតិកាលទី ៧ នៃរដ្ឋសភា នៅតែបន្តផ្តល់ការយកចិត្តទុកដាក់ខ្ពស់ លើការដំឡើងបៀវត្សជូនមន្ត្រីរាជការគ្រប់ប្រភេទ ។

ទន្ទឹមនេះ, ប្រាក់សោធនប្រចាំខែរបស់និវត្តជន ជាអតីតមន្ត្រីរាជការស៊ីវិល និង អតីតយុទ្ធជន, រួមទាំងជនបាត់បង់សមត្ថភាពការងារ និង ជនពិការ, ក៏ត្រូវបានដំឡើង ជាបន្តបន្ទាប់, ជាពិសេស ប្រាក់សោធនអប្បបរមា ។ ជាក់ស្តែង, ប្រាក់សោធនអប្បបរមា ប្រចាំខែរបស់អតីតមន្ត្រីរាជការស៊ីវិល និង អតីតយុទ្ធជន ត្រូវបានដំឡើងជាបន្តបន្ទាប់ ចាប់ពីប្រមាណ ៣០ ម៉ឺនរៀល ក្នុងឆ្នាំ ២០១៥ រហូតដល់ ៧៧ ម៉ឺនរៀល នៅឆ្នាំ ២០២៣ ។ លើសពីនេះ, គម្លាតរវាងអ្នកចូលនិវត្តចាស់, ពោលគឺ អ្នកចូលនិវត្តនៅមុនឆ្នាំ ២០១៥, និង អ្នកចូលនិវត្តថ្មី នៅក្រោយឆ្នាំ ២០១៥, នឹងត្រូវលុបបំបាត់ នៅក្នុងឆ្នាំ ២០២៤ នេះ តាមរយៈការដាក់ចេញនូវវិធានការធ្វើសមាហរណកម្មប្រាក់សោធន តាមប្រព័ន្ធបៀវត្សចាស់ ចូលទៅក្នុងប្រព័ន្ធបៀវត្សថ្មី ។ ផ្អែកតាមច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រង ឆ្នាំ ២០២៤, ឥណទានថវិកា ចំនួន ១០០ ប៊ីលានរៀល, ឬ ប្រមាណ ២៥ លានដុល្លារអាម៉េរិក, ត្រូវបានគ្រោងសម្រាប់ការដំឡើងប្រាក់សោធន និង ការលុបបំបាត់គម្លាត រវាងអ្នកចូលនិវត្តចាស់ និង អ្នកចូលនិវត្តថ្មី ។ ការណ៍នេះធ្វើឱ្យប្រាក់សោធនអប្បបរមាប្រចាំខែរបស់អតីតមន្ត្រីរាជការស៊ីវិល និង អតីតយុទ្ធជន ឡើងដល់ ៨២ ម៉ឺន ៥ ពាន់រៀល នៅឆ្នាំ ២០២៤ នេះ ។

បន្ថែមលើការបន្តពិនិត្យលទ្ធភាពតម្លើងប្រាក់សោធនជាប្រចាំ, រាជរដ្ឋាភិបាល ក៏បានផ្តល់ជូននិវត្តជនគ្រប់រូបដែលជាអតីតមន្ត្រីរាជការ និង អតីតយុទ្ធជន នូវរបបឧបត្ថម្ភសម្រាប់អ្នកនៅក្នុងបន្ទុក, រួមមានសហព័ទ្ធ និង កូនក្នុងបន្ទុក, ព្រមទាំងការគាំពារផ្នែកថែទាំសុខភាព តាមរយៈបេឡាជាតិសន្តិសុខសង្គម ដោយរដ្ឋជាអ្នករ៉ាប់រងបន្ទុកចំណាយបង់ភាគទានទាំងស្រុង ។ មិនតែប៉ុណ្ណោះ, រាជរដ្ឋាភិបាល ក៏បាន និង កំពុងផ្តល់ប្រាក់ឧបត្ថម្ភប្រចាំខែ ជូនដល់និវត្តជនដែលមានជីវភាពលំបាក, ជនចាស់ជរា, និង ប្រជាពលរដ្ឋផ្សេងទៀត រួមមាន៖ ជនមានពិការភាព, ស្ត្រីមានផ្ទៃពោះ, កុមារក្រោមអាយុ ២ ឆ្នាំ និង អ្នកផ្ទុកមេរោគអេដស៍ ដែលសមាជិកគ្រួសារមានប័ណ្ណសមធម៌ តាមរយៈ **កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និង ងាយរងគ្រោះ ក្នុងអំឡុងនៃការប្រយុទ្ធនឹងជំងឺកូវីដ-១៩** ហើយនឹងឈានទៅអនុវត្តបន្ត ជា «**កម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ**» ចាប់ពីខែមេសា ឆ្នាំ ២០២៤ នេះតទៅ ។ តាមរយៈយន្តការនេះ, ក្រុមគោលដៅខាងលើ នឹងអាច

ទទួលបាននូវ ប្រាក់ឧបត្ថម្ភពីបណ្តុំនៃកម្មវិធីឧបត្ថម្ភសាច់ប្រាក់ រួមមាន ៖ ការឧបត្ថម្ភគោលសម្រាប់គ្រួសារ, កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនជនចាស់ជរា (អាយុ ៦០ ឆ្នាំឡើង), កម្មវិធីឧបត្ថម្ភសាច់ប្រាក់ ជូនជនមានពិការភាព, កម្មវិធីឧបត្ថម្ភសាច់ប្រាក់ ជូនស្ត្រីមានផ្ទៃពោះ និង កុមារអាយុក្រោម ២ ឆ្នាំ និង ការឧបត្ថម្ភអ្នកផ្ទុកមេរោគអេដស៍ ។

ជាក្របខណ្ឌរួមនៃរបៀបវារៈគោលនយោបាយសង្គម-សេដ្ឋកិច្ចរបស់ខ្លួន, រាជរដ្ឋាភិបាលនីតិកាលទី ៧ នៃរដ្ឋសភា បានដាក់ចេញ នូវ **យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១** ដើម្បី **កំណើន, ការងារ, សមធម៌, ប្រសិទ្ធភាព, និង ចីរភាព** ដោយរួមបញ្ចូលនូវ **កម្មវិធីគោលនយោបាយអាទិភាព ចំនួន ៦** សម្រាប់អនុវត្តភ្លាម ចាប់តាំងពីដើមនីតិកាល, ដែលក្នុងនោះ **កម្មវិធីគោលនយោបាយអាទិភាព ចំនួន ៤** ផ្តោតលើកិច្ចការគាំពារសង្គម រួមមាន៖

**កម្មវិធីទី ១** : **ការផ្តល់ការថែទាំសុខភាព ឆ្ពោះទៅកម្មវិធីគ្របដណ្តប់សុខភាពជាសកល** ដោយចាប់ផ្តើមពី ៖ (១).ការផ្តល់សេវាថែទាំសុខភាព ជូនគ្រួសារងាយរងហានិភ័យ ប្រមាណជាង ៤៥ ម៉ឺនគ្រួសារ, ដោយក្រសោបសមាជិកសរុបជាង ១,៥ លាននាក់, តាមរយៈការប្រើប្រាស់មូលនិធិសមធម៌សុខាភិបាល; និង (២).ការពង្រីករបបថែទាំសុខភាពរបស់ **ប.ស.ស**, ទាំងសម្រាប់កម្មករ-និយោជិត និង សម្រាប់មន្ត្រីសាធារណៈ ដែលគ្របដណ្តប់បន្ថែម ដល់សមាជិកគ្រួសារ និង អ្នកនៅក្នុងបន្ទុក ប្រមាណជាង ៣ លាននាក់ តាមគោលការណ៍ស្ម័គ្រចិត្ត ។ សរុបមក, គម្រោងទាំងពីរនេះ នឹងធ្វើឱ្យប្រជាជនប្រមាណ ៧,៤ លាននាក់ មានលទ្ធភាពទទួលបាននូវរបបសន្តិសុខសង្គមផ្នែកសេវាថែទាំសុខភាព ។

**កម្មវិធីទី ២** : **ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និង បច្ចេកទេស ជូនដល់យុវជនមកពីគ្រួសារក្រីក្រ និង គ្រួសារងាយរងហានិភ័យនៅទូទាំងប្រទេស** ដែលមានចំនួនប្រមាណជាង ១,៥ លាននាក់ នៅតាមបណ្តាគ្រឹះស្ថានបណ្តុះបណ្តាលវិជ្ជាជីវៈនានារបស់រដ្ឋ ក្នុងកម្រិតសញ្ញាបត្របច្ចេកទេស និង វិជ្ជាជីវៈ កម្រិត ១ ដោយមិនបង់ថ្លៃសិក្សា និង ទទួលបាននូវប្រាក់ឧបត្ថម្ភប្រចាំខែ ចំនួន **២៨ ម៉ឺនរៀល** បន្ថែមទៀត ។

**កម្មវិធីទី ៣** : **ការធ្វើស្ថាបនូបនីយកម្មកម្មវិធីជាតិជំនួយសង្គម សម្រាប់គ្រួសារក្រីក្រ, ក្រុមជនងាយរងគ្រោះ នៅក្នុងគ្រួសារក្រីក្រ និង គ្រួសារងាយរងហានិភ័យ ក្នុងគ្រាមានវិបត្តិសេដ្ឋកិច្ច និង គ្រាមានគ្រោះអាសន្ន** ដើម្បីជួយទ្រទ្រង់ និង ផ្តល់ការគាំពារទាន់ពេល និង ក្នុងលក្ខណៈជាប្រព័ន្ធ ជូនប្រជាពលរដ្ឋ, ជាពិសេស គ្រួសារក្រីក្រ និង ងាយរងគ្រោះ និង

គ្រួសារងាយរងហានិភ័យ, ទៅតាមស្ថានភាពជាក់ស្ដែងនៃវិបត្តិ ឬ គ្រោះអាសន្ន នៅតាមគ្រប់ទីតាំងភូមិសាស្ត្រទូទាំងប្រទេស ដែលនឹងគ្របដណ្ដប់លើប្រជាជន សរុបប្រមាណ ៤,៣ លាននាក់ ។

**កម្មវិធីទី ៤** : **ការដាក់ចេញ និង ការជំរុញអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ ឱ្យមានលទ្ធភាពចូលរួមក្នុងសេដ្ឋកិច្ចក្នុងប្រព័ន្ធ និង អាចទទួលបានផលប្រយោជន៍ ពីប្រព័ន្ធគាំពារសង្គមផ្លូវការ** តាមរយៈ ៖ (១).ការផ្ដល់នូវការគាំពារ និង ការបង្កើតនូវបរិយាកាសអំណោយផល សម្រាប់ធ្វើធុរកិច្ច និង ពាណិជ្ជកម្ម ព្រមជាមួយនឹងការផ្ដល់នូវការបណ្ដុះបណ្ដាលជំនាញបច្ចេកទេស និង វិជ្ជាជីវៈដល់ក្រុមហ៊ុន, សហគ្រាសធុនមីក្រូ, តូច និង មធ្យម; និង (២).ការផ្ដល់ការគាំពារសង្គម ដល់បុគ្គលស្វ័យនិយោជន៍ ក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ ដោយផ្ដោតការយកចិត្តទុកដាក់ជាបឋម លើការផ្ដល់សេវាថែទាំសុខភាព នៅក្រោមមូនិធិសមធម៌សុខាភិបាល ។

## ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី !

ជោគជ័យគួរជាទីមោទនៈទាំងឡាយ ក្នុងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ដែលសម្រេចបានមកនៅក្រោមម្លប់ដ៏ត្រជាក់នៃសុខសន្តិភាព ក្នុងរយៈពេល ២៦ ឆ្នាំកន្លងទៅ, ពិសេសសមិទ្ធផល នៃការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្នុងរយៈពេលប្រមាណ ២០ ឆ្នាំចុងក្រោយនេះ គឺជាស្នាដៃដែលបានមកពីការចូលរួមសស្រាក់សស្រាំ ពីសំណាក់ថ្នាក់ដឹកនាំ និង មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ, ក្រសួង-ស្ថាប័នពាក់ព័ន្ធ និង ដៃគូអភិវឌ្ឍន៍នានា, ដោយមានការចូលរួមចំណែកមិនអាចខ្វះបាន ពីសំណាក់លោកអ៊ំ, លោកពូ, អ្នកមីង និង បងៗ ជានិវត្តជនទាំងអស់ ដែលបានលះបង់ នូវកម្លាំងកាយ-ចិត្ត និង ប្រាជ្ញា-ស្មារតី ក្នុងការបម្រើជាតិ និង ប្រជាជន នាពេលកន្លងទៅ ។ ទោះបីស្ថិតនៅក្នុងដំណាក់កាលដែលប្រទេសយើងជួបការលំបាកយ៉ាងណាក្ដី, ក៏មន្ត្រីរាជការរបស់យើង នៅតែខិតខំពុះពារជម្នះគ្រប់ឧបសគ្គ ក្នុងការបម្រើក្រសួង និង បានចូលរួមចំណែកក្នុងការអភិវឌ្ឍប្រទេសជាតិ រហូតទទួលបានលទ្ធផលជាផ្លែផ្កា គួរជាទីមោទនៈ ដូចបច្ចុប្បន្ន ។

ក្នុងន័យនេះ, ដូចខ្ញុំបានគូសបញ្ជាក់ខាងលើ, ក្រសួងបានរៀបចំពិធីជួបជុំ នាថ្ងៃនេះ ដើម្បីសម្ដែងនូវការដឹងគុណ និង ការតបស្នងឧបការគុណ ដល់និវត្តជនទាំងអស់ ក៏ដូចជាដើម្បីរំលឹកអនុស្សាវរីយ៍ និង បង្កើតឱកាសសម្រាប់ជំនួប រវាងមិត្តចាស់រួមជំនាន់ ដែល

ធ្លាប់បានបម្រើការងារជាមួយគ្នា និង ប្រកៀកស្មាគ្នា, ក្នុងស្មារតីសាមគ្គីភាព និង ភាតរភាព, ក្នុងការបំពេញភារកិច្ចជូនក្រសួង និង រាជរដ្ឋាភិបាល ក៏ដូចជា ជូនប្រទេសជាតិទាំងមូល ។ នៅក្នុងពិធីជួបជុំនាថ្ងៃនេះ, យើងក៏ចង់បង្ហាញជូននិវត្តជនទាំងអស់ថា យើងខ្ញុំនៅតែនឹក-រលឹក និង ចងចាំជានិច្ច នូវរាល់ស្នាដៃ និង គុណូបការៈដែលលោកអ៊ំ, លោកពូ, អ្នកមីង និង បងៗ ជាអតីតមន្ត្រីរាជការក្រោមឱវាទក្រសួង បានចូលរួមក្នុងការអភិវឌ្ឍវិស័យសេដ្ឋកិច្ច និង ហិរញ្ញវត្ថុរបស់ជាតិ ក្នុងមួយជីវិតការងាររបស់ខ្លួន ។

ថ្វីត្បិតថ្ងៃនេះ, និវត្តជនទាំងអស់មិនបានចូលរួមក្តី, ជាពិសេស និវត្តជននៅតាមបណ្តាអង្គភាពនៅថ្នាក់មូលដ្ឋាន, ក៏កន្លងមក, ក្នុងនាមជាតំណាងរបស់ខ្ញុំ, លោកជំទាវ **កែវ ចរិយា** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ជាប្រធានក្រុមប្រឹក្សាភិបាលសមាគមសង្គហៈមិត្ត, និង ឯកឧត្តម **យ៉េត វិរៈណៃល** អនុរដ្ឋលេខាធិការក្រសួងសេដ្ឋ-កិច្ច និង ហិរញ្ញវត្ថុ និង ជាប្រធានគណៈកម្មការប្រតិបត្តិសមាគម សង្គហៈមិត្ត, បានដឹកនាំក្រុមការងារសមាគមសង្គហៈមិត្ត ចុះសួរសុខទុក្ខនិវត្តជន នៅតាមបណ្តាខេត្តទូទាំងប្រទេសជាបន្តបន្ទាប់ ។ ជាការពិត, ការចុះសួរសុខទុក្ខនៅតាមបណ្តាខេត្ត ត្រូវបានធ្វើឡើងនៅតាមទីកន្លែងដែលនិវត្តជនរស់នៅផ្ទាល់ ដើម្បីកុំឱ្យលោកអ៊ំ, លោកពូ, អ្នកមីង និង បងៗ ជានិវត្តជន មានការលំបាក ក្នុងការធ្វើដំណើរមកដល់រាជធានីភ្នំពេញ ។

## ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី !

មុននឹងបញ្ចប់, ខ្ញុំក៏សូមយកឱកាសនេះ កោតសរសើរ និង វាយតម្លៃខ្ពស់ ចំពោះឯកឧត្តម, លោកជំទាវ, លោក, លោកស្រី, ជាប្រធាន, អនុប្រធាន, សមាជិក-សមាជិកានៃក្រុមប្រឹក្សាភិបាល, គណៈកម្មការប្រតិបត្តិសមាគមសង្គហៈមិត្ត និង អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដែលបានខិតខំបំពេញការងារជាប្រយោជន៍ ដល់មន្ត្រីរាជការ និង និវត្តជននៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ, ជាពិសេស ការចូលរួមក្នុងគ្រប់សកម្មភាពនានា ដែលបម្រើដល់ចក្ខុវិស័យរបស់សមាគមសង្គហៈមិត្ត ឱ្យមានការរីក-ចម្រើន ពីមួយឆ្នាំទៅមួយឆ្នាំ ។

សម្រាប់លោកអ៊ំ, លោកពូ, អ្នកមីង និង បងៗ ជានិវត្តជន ដែលបានអញ្ជើញចូលរួមក្នុងពិធីជួបជុំ នាថ្ងៃនេះ សរុបចំនួនប្រមាណ ៥០០ នាក់, ម្នាក់ៗនឹងទទួលបាននូវថវិកាចំនួន ២០ ម៉ឺនរៀល ដែលជាថវិការបស់សមាគមសង្គហៈមិត្ត ព្រមទាំងសំពត់ ១ ក្បិន និង ក្រម៉ា ១ ដែលជាអំណោយរបស់គណៈកម្មការសាខាសមាគមនារីកម្ពុជា ដើម្បីសន្តិភាព

និង អភិវឌ្ឍន៍ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។ និវត្តជន ដែលមិនបានអញ្ជើញចូលរួម នាថ្ងៃនេះ ក៏នឹងទទួលបានថវិកាចំនួន ២០ ម៉ឺនរៀល, សំពត់ ១ ក្បិន និង ក្រម៉ា ១ ដូចគ្នា ផងដែរ, ដែលនឹងត្រូវផ្តល់ជូន តាមរយៈសាខាសមាគមសង្គហៈមិត្តនីមួយៗ នាពេលបន្ទាប់ ។

នៅទីបញ្ចប់, ក្នុងឱកាសនៃពិធីបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិខ្មែរ, ឆ្នាំរោង ឆស័ក ពុទ្ធសករាជ ២៥៦៨, ដែលនឹងឈានចូលមកដល់ក្នុងពេលដ៏ខ្លីខាងមុខ, ខ្ញុំសូមប្រសិទ្ធ-ពរជ័យជូន ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី, ជាថ្នាក់ដឹកនាំក្រសួង និង មន្ត្រី-រាជការ, ជាពិសេស និវត្តជនទាំងអស់ បានប្រកបដោយពុទ្ធពរ និង ពរ ទាំងប្រាំប្រការ គឺៈ អាយុ, វណ្ណៈ, សុខៈ, ពលៈ និង បដិភាណៈ កុំបីឃ្លៀងឃ្លាតឡើយ ៕

***សូមអរគុណ !***